**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**

សំណុំរឿងរដ្ឋប្បវេណីលេខ: ២៦១
ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣

**សាលក្រមរដ្ឋប្បវេណី**
**លេខ: ០៥ "ង"**
ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤

# សាលក្រម
# ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបើកនីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈ **នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤** លើសំណុំរឿងរដ្ឋប្បវេណីលេខ: **២៦១** ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២៣ ដោយមានសមាសភាពជំនុំជម្រះដូចខាងក្រោម:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**ភាគីដើមចោទ៖** ឈ្មោះ [redacted] **ស្រង់** ភេទស្រី កើតនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៧៣ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ: ១០១១៧៥៩៦០ ចាំថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ មានអាសយដ្ឋានបច្ចុប្បន្ននៅ [redacted] ។

**អ្នកតំណាងដោយអាណត្តិ៖** មេធាវីឈ្មោះ [redacted] មេធាវីឈ្មោះ [redacted] និងមេធាវីឈ្មោះ [redacted] ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៃការិយាល័យមេធាវី [redacted] មានអាសយដ្ឋាននៅផ្ទះ [redacted] ។

**និងចុងចម្លើយ៖** ឈ្មោះ [redacted] **ចន្ថា** ភេទប្រុស កើតនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧០ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ: ១០០៩២៦៤៥៧ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៨ មានអាសយដ្ឋានបច្ចុប្បន្ននៅ [redacted]

**អ្នកតំណាងដោយអាណត្តិ៖** "គ្មាន" ។

## ក.អង្គហេតុ និងចំណុចវិវាទ

### ១. ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទឱ្យតុលាការចេញ៖

១.១.សុំផ្តាច់អនីតិសង្វាសជាលក្ខណៈប្តីប្រពន្ធរវាងឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ស្រង់ ។

១.២.បែងចែកទ្រព្យសម្បត្តិរួមប្តីប្រពន្ធចំនួនពាក់កណ្តាលម្នាក់នូវអចលនវត្ថុចំនួន **១០** (ដប់) កន្លែង ដែលមានដូចខាងក្រោម៖

**ក**.អចលនវត្ថុទី១៖ ទំហំ **៤៦១** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិស្ទឹង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ: **តក ០០២៥៥៧** ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០២ ចេញដោយមន្ទីររៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ ។

**ខ**.អចលនវត្ថុទី២៖ ទំហំ **៩០** ម៉ែត្រ គុណ ៣០ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិរស្សីគុម្ព ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ: **០២៦/១៥ បជ** ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ចេញដោយមេឃុំអូរសារាយ ។

**គ**.អចលនវត្ថុទី៣៖ ទំហំ **៣,១៥០.៣៤** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្ពង់ ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្តាច់លេខ: **៧៣៩/២១ បជ** ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ។



Scanned with CamScanner

**ឃ**.អចលនវត្ថុទី៤៖ ទំហំ **៥៥៦៩៤** ម៉ែត្រការ៉េ ក្បាលដីលេខៈ **១៧០២** មានទីតាំងស្ថិតនៅភូមិកំណប់ ឃុំស្រែចែង ស្រុកជុំគិរី ខេត្តកំពត មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ **០៧០៤០៤០១-១៧០២** ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ចេញដោយមន្ទីររៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត ។

**ង**.អចលនវត្ថុទី៥៖ ទំហំ **១,៧៧៧.៣៦** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងក្ត ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតបញ្ជាក់សុំកាន់កាប់ប្រើប្រាស់ដីលេខៈ **២៧៨/២៨ បជ** ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ចេញដោយមេឃុំអូរសារាយ ។

**ច**.អចលនវត្ថុទី៦៖ ទំហំ **២៨៨** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្ពង់ ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតលក់ផ្តាច់លេខៈ **៨៥៤/១៣ បជ** ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ ។

**ឆ**.អចលនវត្ថុទី៧៖ ទំហំ **៣,២៥៣.៥៤** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្ពង់ ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្តាច់លេខៈ **៣០៣២/២១ បជ** ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ ។

**ជ**.អចលនវត្ថុទី៨៖ ទំហំ **៥.៤១៦** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្ពង់ ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្តាច់លេខៈ **៣០១៥/១៨ បជ** ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

**ឈ**.អចលនវត្ថុទី៩៖ ទំហំ **៦៥៣.៥** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្ពង់ ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតលក់ផ្តាច់លេខៈ **០០៦៥/១៦ បជ** ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ។

**ញ**.អចលនវត្ថុទី១០៖ គ្មានទំហំ មានទីតាំងស្ថិតនៅភូមិស្ទឹង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្តាច់លេខៈ **៣០១៦/១៨ បជ** ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ។

**១.៣**.បំណុលរួមប្តីប្រពន្ធដែលនៅជំពាក់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) សរុបចំនួន **៤00.000** (**សែសិបម៉ឺន**) **ដុល្លាអាមេរិក** ទទួលខុសត្រូវសងរួមគ្នា ។

## ២. <u>**ការពន្យល់ត្រួសៗអំពីរឿងក្តី**</u>

កាលអំឡុងឆ្នាំ១៩៨៩ ដើមចោទ និងចុងចម្លើយបានរួមរស់ជាមួយគ្នា និងមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ឡើយ ការរស់នៅជាមួយគ្នាពួកគេមានកូនស្រីម្នាក់ (មាននីតិភាព) និងមានទ្រព្យសម្បត្តិជាដីចំនួន ១០ (ដប់) កន្លែង និងបំណុលរួមប្តីប្រពន្ធដែលនៅជំពាក់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) សរុបចំនួន **៤00.000** (**សែសិបម៉ឺនដុល្លាអាមេរិក**) ។ ទើបរយៈពេលចុងក្រោយនេះពួកគេមានភាពមិនចុះសម្រុងនឹងគ្នា មានការខ្វែងគំនិតគ្នា មានវាយដំដើមចោទ ហើយចុងចម្លើយមានប្រពន្ធថ្មីទៀត តែងតែចុះចោលផ្ទះ ពេលស្រវឹងតែងតែរករឿងដើមចោទ ជាហេតុធ្វើឱ្យដើមចោទអស់មនោសញ្ចេតនានឹងរួមរស់ជាប្តីប្រពន្ធតទៅទៀត ដែលជាហេតុធ្វើឱ្យដើមចោទសម្រេចចិត្តដាក់ពាក្យបណ្តឹងលែងលះនៅពេលនេះ ។

## ៣. **អង្គហេតុដែលអះអាងដោយដើមចោទ**

<u>**ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា:**</u> ខ្លួនបានរួមរស់ជាមួយចុងចម្លើយតាំងពីអំឡុងឆ្នាំ១៩៨៩ និងមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ឡើយ ។ ការរស់នៅជាមួយគ្នាពួកយើងមានកូនស្រីម្នាក់ (មាននីតិភាព) និងមានទ្រព្យសម្បត្តិជាដីចំនួន ១០ កន្លែង និងបំណុលរួមប្តីប្រពន្ធដែលនៅជំពាក់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) សរុបចំនួន **៤00.000** (**សែសិបម៉ឺន**) **ដុល្លាអាមេរិកគត់** ។ ទើបរយៈពេលចុងក្រោយនេះពួកយើងមានភាពមិនចុះសម្រុងនឹងគ្នា មានការខ្វែងគំនិតគ្នា វាយដំខ្លួន ហើយគាត់មានប្រពន្ធថ្មីទៀត តែងតែចុះចោលផ្ទះ ពេលស្រវឹងតែងតែរករឿងខ្លួន ជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនានឹងរួមរស់ជាប្តីប្រពន្ធតទៅទៀត ។ ការរស់នៅជាមួយគ្នាកន្លងមក ខ្លួន និងចុងចម្លើយ បានបង្កើតកូនចំនួន ០១ (មួយ) នាក់ គឺឈ្មោះ [redacted] ស្រីល័ក្ខ អាយុ ៣២ ឆ្នាំ ។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ខ្លួន និងចុងចម្លើយ មានទ្រព្យសម្បត្តិរួម និងបំណុលរួម ដូចខាងក្រោម៖

**ក**.អចលនវត្ថុទី១៖ ទំហំ **៤៦១** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិស្ទឹង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខៈ **តក ០០២៥៥៧** ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០២ ចេញដោយមន្ទីររៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ ។

**ខ**.អចលនវត្ថុទី២៖ ទំហំ **៩០** ម៉ែត្រ គុណ ៣០ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិរស្សីគុម្ព ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខៈ **០២៦/១៥ បជ** ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ចេញដោយមេឃុំអូរសារាយ ។



Scanned with CamScanner

គ.អចលនវត្ថុទី៣៖ ទំហំ **៣,១៥០.៣៤** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទូលខ្លង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្តាច់លេខ: **៧៣៩/២១ បផ** ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ។

**ឃ**.អចលនវត្ថុទី៤៖ ទំហំ **៥៥៦៩៤** ម៉ែត្រការ៉េ ក្បាលដីលេខ: **១៧០២** មានទីតាំងស្ថិតនៅភូមិកំណប់ ឃុំស្រែចែង ស្រុកជុំគិរី ខេត្តកំពត មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: **០៧០៤០៤០១-១៧០២** ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ចេញដោយមន្ទីររៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត ។

**ង**.អចលនវត្ថុទី៥៖ ទំហំ **១,៧៧៧.៣៦** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងក្ល ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតបញ្ជាក់សុំកាន់កាប់ប្រើប្រាស់ដីលេខ: **២៧៨/២៨ បផ** ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ចេញដោយមេឃុំអូរសារាយ ។

**ច**.អចលនវត្ថុទី៦៖ ទំហំ **២៨៨** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទូលខ្លង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតលក់ផ្តាច់លេខ: **៨៥៤/១៣ បផ** ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ ។

**ឆ**.អចលនវត្ថុទី៧៖ ទំហំ **៣,២៥៣.៥៤** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទូលខ្លង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្តាច់លេខ: **៣០៣២/២១ បផ** ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ ។

**ជ**.អចលនវត្ថុទី៨៖ ទំហំ **៥.៤១៦** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទូលខ្លង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្តាច់លេខ: **៣០១៥/១៨ បផ** ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

**ឈ**.អចលនវត្ថុទី៩៖ ទំហំ **៦៥៣.៥** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទូលខ្លង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតលក់ផ្តាច់លេខ: **០០៦៥/១៦ បផ** ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ។

**ញ**.អចលនវត្ថុទី១០៖ គ្មានទំហំ មានទីតាំងស្ថិតនៅភូមិស្ទឹង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្តាច់លេខ: **៣០១៦/១៨ បផ** ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ។ សុំឱ្យតុលាការបែងចែកជាពីរចំណែកស្មើៗគ្នា ។

និងបំណុលរួមប្តីប្រពន្ធដែលនៅជំពាក់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) សរុបចំនួន **៤០០.០០០** (**សែសិបម៉ឺន**) **ដុល្លារអាមេរិក** សុំឱ្យតុលាការបែងចែកជាពីរចំណែកស្មើៗគ្នា ។

### ៤. <u>អង្គហេតុដែលអះអាងដោយចុងចម្លើយ</u>

<u>**ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា:**</u> អវត្តមានដោយគ្មានមូលហេតុគ្រប់គាលបរិច្ឆេទនីតិវិធី និងទទួលបានដីកាកោះត្រឹមត្រូវរួចហើយ យោងតាមរបាយការណ៍បញ្ជូនរបស់ប្រៃសណីយ៍កម្ពុជា ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ និងរបាយការណ៍បញ្ជូនរបស់ប្រៃសណីយ៍កម្ពុជា ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣។

### ៥. <u>ចំណុចគ្មានវិវាទ</u>

-គ្មាន ។

### ៦. <u>ចំណុចវិវាទ</u>

**៦.១**.តើអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយ ជាអាពាហ៍ពិពាហ៍ស្របតាមច្បាប់ ហើយពិតជាបាក់បែកមិនអាចធ្វើបដិទានវិញបាន មែនដែរឬទេ?

**៦.២**.តើការបែងចែកទ្រព្យសម្បត្តិរួម និងបំណុលរួមមានយុត្តិធម៌សម្រាប់ភាគីដែរឬទេ?

## ខ. <u>ការពិនិត្យភស្តុតាង</u>

### ១. <u>ភស្តុតាងជាឯកសាររបស់ដើមចោទ</u>

**១.១**.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: **០៧០៤០៤០១-១៧០២** ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ។

**១.២**.លិខិតផ្ទេរសិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ: **០២៦/១៥ប.ផ** ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ។

**១.៣**.លិខិតលក់ផ្តាច់លេខ: **៧៣៩/២១ ប.ផ** ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ។

**១.៤**.លិខិតបញ្ជាក់សិទ្ធិកាន់កាប់ប្រើប្រាស់ដីលេខ: **២៧៨/២៨ ប.ផ** ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ។

**១.៥**.លិខិតលក់ផ្តាច់លេខ: **៨៥៤/១៣ ប.ផ** ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៣ និងលិខិតផ្ទេរសិទ្ធិកាន់កាន់ដីលេខ: **៨៥៥/១៣ ប.ផ** ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៣ ។



Scanned with CamScanner

១.៦.លិខិតលក់ផ្តាច់លេខៈ ៣០៣២/២១ ប.ផ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ ។

១.៧.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខៈ គក០០២៥៥៧ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០២ ។

១.៨.លិខិតលក់ដីលេខៈ ៣០១៦/១៨ ប.ផ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

១.៩.លិខិតលក់ផ្តាច់លេខៈ ០០៦៥/១៦ ប.ផ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ។

១.១០.លិខិតលក់ផ្តាច់លេខៈ ៣០១៥/១៨ ប.ផ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

**២.ភស្តុតាងជាឯកសាររបស់ចុងចម្លើយ**

-"គ្មាន" ។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង **តុលាការយល់ឃើញថាៈ**

១.ពាក្យបណ្តឹងចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ របស់ដើមចោទ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ តាមបញ្ញត្តិមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២.ផ្អែកតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ បានបញ្ជាក់ថាៈ ខ្លួន និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណីខ្មែរ កាលអំឡុងឆ្នាំ១៩៨៩ និងមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ តុលាការយល់ឃើញថា អាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយជាអាពាហ៍ពិពាហ៍មិនស្របច្បាប់តាមបញ្ញត្តិមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី នោះទេ ដូចនេះការសុំផ្តាច់អនីតិសង្វាស ជាលក្ខណៈប្តីប្រពន្ធរវាងឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ស្រង់ មិនមានភាពចាំបាច់ណា ដែលត្រូវការសេចក្តីសម្រេចពីតុលាការទៀតឡើយ ព្រោះអ្នកទាំងពីរច្បាប់ចាត់ទុកជាប្តីប្រពន្ធមិនស្របច្បាប់រួចទៅហើយ ដូច្នេះគប្បីតុលាការពិចារណា និងសម្រេចច្រានចោលការទាមទារត្រង់ចំណុចទី១ នៃពាក្យបណ្តឹងដែលសុំផ្តាច់អនីតិសង្វាសជាលក្ខណៈប្តីប្រពន្ធរវាងឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ស្រង់ ។

៣.ដើមចោទ និងចុងចម្លើយ ជាប្តីប្រពន្ធដែលមិនមានសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ក៏ពិតមែន ប៉ុន្តែយោងតាមស្ថានភាពជាក់ស្តែងដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ ត្រឹមត្រូវតាមប្រពៃណីខ្មែរ ជាមួយគ្នាតាំងពីឆ្នាំ១៩៨៩ ហើយកាលពីអំឡុងឆ្នាំនោះ ប្រជាពលរដ្ឋទូទៅមិនមានការយល់ដឹងអំពីការចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ ហើយការរួមរស់នៅជាមួយគ្នារវាងដើមចោទ និងចុងចម្លើយមកដល់បច្ចុប្បន្ន ពិតជាមិនអាចបន្តទៅមុខទៀតបាន ពិតប្រាកដមែន ដោយដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នាតទៅមុខទៀតបាន ហើយទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ គ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន ហើយដើមចោទ និងចុងចម្លើយពិតជាបានទិញអចលនវត្ថុរួមគ្នា ដែលគប្បីឱ្យតុលាការធ្វើការបែងចែកពិតប្រាកដមែន ដូច្នេះគប្បីតុលាការពិចារណា និងសម្រេចធ្វើការបែងចែកអចលនវត្ថុនោះតាមការទាមទាររបស់ដើមចោទ ដោយយោងទៅតាមបញ្ញត្តិមាត្រា ២, មាត្រា ៤ និងមាត្រា ១៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៤.ផ្អែកតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ និងផ្អែកតាមឯកសារជាភស្តុតាងរបស់ដើមចោទដែលដាក់ជូនតុលាការពិនិត្យ បង្ហាញឱ្យឃើញថាៈ អចលនវត្ថុដូចដែលមានដូចខាងក្រោមៈ

ក.អចលនវត្ថុទី១ៈ ទំហំ ៤៦១ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិស្ទឹង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខៈ គក ០០២៥៥៧ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០២ ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ ។

ខ.អចលនវត្ថុទី២ៈ ទំហំ ៩០ ម៉ែត្រ គុណ ៣០ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិរស្សីតុម្ព ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខៈ ០២៦/១៥ បផ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ចេញដោយមេឃុំអូរសារាយ ។

គ.អចលនវត្ថុទី៣ៈ ទំហំ ៣,១៥០.៣៤ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្លុង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្តាច់លេខៈ ៧៣៩/២១ បផ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ។



Scanned with CamScanner

**ឃ**.អចលនវត្ថុទី៤៖ ទំហំ **៥៥៦៩៤** ម៉ែត្រការ៉េ ក្បាលដីលេខៈ **១៧០២** មានទីតាំងស្ថិតនៅភូមិកំណប់ ឃុំស្រែចែង ស្រុកជុំគិរី ខេត្តកំពត មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ **០៧០៤០៤០១-១៧០២** ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត ។

**ង**.អចលនវត្ថុទី៥៖ ទំហំ **១,៧៧៧.៣៦** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងត្លុ ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតបញ្ជាក់សុំកាន់កាប់ប្រើប្រាស់ដីលេខៈ **២៧៨/២៨ បជ** ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ចេញដោយមេឃុំអូរសារាយ ។

**ច**.អចលនវត្ថុទី៦៖ ទំហំ **២៨៨** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្លុង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតលក់ផ្តាច់លេខៈ **៨៥៤/១៣ បជ** ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ ។

**ឆ**.អចលនវត្ថុទី៧៖ ទំហំ **៣,២៥៣.៥៤** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្លុង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្តាច់លេខៈ **៣០៣២/២១ បជ** ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ ។

**ជ**.អចលនវត្ថុទី៨៖ ទំហំ **៥.៤១៦** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្លុង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្តាច់លេខៈ **៣០១៥/១៨ បជ** ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

**ឈ**.អចលនវត្ថុទី៩៖ ទំហំ **៦៥៣.៥** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្លុង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតលក់ផ្តាច់លេខៈ **០០៦៥/១៦ បជ** ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ។

**ញ**.អចលនវត្ថុទី១០៖ គ្មានទំហំ មានទីតាំងស្ថិតនៅភូមិស្ទឹង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្តាច់លេខៈ **៣០១៦/១៨ បជ** ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ។

ពិតជាមានឈ្មោះដើមចោទ និងចុងចម្លើយជាម្ចាស់កម្មសិទ្ធិអវិភាគ ពិតប្រាកដមែន ដូច្នេះអ្នកទាំងពីរ ពិតជាមានទ្រព្យសម្បត្តិរួមជាមួយគ្នា ពិតប្រាកដមែន និងដើម្បីជាប្រយោជន៍ដល់ភាគី គប្បីតុលាការពិចារណា និងសម្រេចបែងចែក **១ ភាគ ២ (មួយភាគពីរ)** នៃទ្រព្យសម្បត្តិរួមជាអចលនវត្ថុដូចខាងលើ តាមបញ្ញត្តិមាត្រា **២២** នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទង ទៅនឹងឋានៈបុគ្គល និងតាមបញ្ញត្តិមាត្រា **២១១**, មាត្រា **២១២** និងមាត្រា **៩៨០** នៃក្រមរដ្ឋប្បវេណី ។

**៥**.ផ្អែកតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ បានបញ្ជាក់ថាៈ ខ្លួន និងចុងចម្លើយមានបំណុលរួមជាមួយគ្នា ដែលនៅជំពាក់ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) សរុបចំនួន **៤០០.០០០ (សែសិបម៉ឺន) ដុល្លារអាមេរិក** ហើយដើម្បីជៀសវាងការបែងចែកបំណុលខាងលើប៉ះពាល់ទៅដល់ម្ចាស់បំណុលដទៃទៀត ដូច្នេះគប្បីតុលាការពិចារណា និងសម្រេចច្រានចោលការទាមទារត្រង់ចំណុចទី៣ នៃកម្មវត្ថុពាក្យបណ្តឹង តាមបញ្ញត្តិមាត្រា **២២** នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងទៅនឹងឋានៈបុគ្គល និងតាមបញ្ញត្តិមាត្រា **៩៨០** នៃក្រមរដ្ឋប្បវេណី ។

**៦**.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ តាមបញ្ញត្តិមាត្រា **៦៤** នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

**១**.ច្រានចោលការទាមទារត្រង់ចំណុចទី**១** និងទី**៣** នៃកម្មវត្ថុពាក្យបណ្តឹង ។

**២**.បែងចែកអចលនវត្ថុចំនួន **១០** (ដប់) កន្លែង ដូចខាងក្រោម៖

**ក**.អចលនវត្ថុទី១៖ ទំហំ **៤៦១** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិស្ទឹង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខៈ **តក ០០២៥៥៧** ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០២ ចេញដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តតាកែវ ដែលជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និងចុងចម្លើយ ក្នុងចំណែកម្នាក់ៗចំនួន **១ ភាគ ២ (មួយភាគពីរ)** ។

**ខ**.អចលនវត្ថុទី២៖ ទំហំ **៩០** ម៉ែត្រ គុណ **៣០** ម៉ែត្រ មានទីតាំងស្ថិតនៅភូមិឬស្សីគុម្ព ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខៈ **០២៦/១៥ បជ** ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ចេញដោយមេឃុំអូរសារាយ ដែលជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និងចុងចម្លើយ ក្នុងចំណែកម្នាក់ៗ ចំនួន **១ ភាគ ២ (មួយភាគពីរ)** ។



Scanned with CamScanner

គ.អចលនវត្ថុទី៣៖ ទំហំ ៣,១៥០.៣៤ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្លុង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្ដាច់លេខ: **៧៣៩/២១ បជ** ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ដែលជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និងចុងចម្លើយ ក្នុងចំណែកម្នាក់ៗចំនួន **១ ភាគ ២** ( **មួយភាគពីរ** ) ។

ឃ.អចលនវត្ថុទី៤៖ ទំហំ **៥៥៦៩៤** ម៉ែត្រការ៉េ ក្បាលដីលេខ: **១៧០២** មានទីតាំងស្ថិតនៅភូមិកំណប់ ឃុំស្រែចែង ស្រុកជុំគិរី ខេត្តកំពត មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: **០៧០៤០៤០១-១៧០២** ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៤ ចេញដោយមន្ទីររៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពត ដែលជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និងចុងចម្លើយ ក្នុងចំណែកម្នាក់ៗចំនួន **១ ភាគ ២** ( **មួយភាគពីរ** ) ។

ង.អចលនវត្ថុទី៥៖ ទំហំ **១,៧៧៧.៣៦** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងក្ដួ ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតបញ្ជាក់សុំកាន់កាប់ប្រើប្រាស់ដីលេខ: **២៧៨/២៨ បជ** ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ ចេញដោយមេឃុំអូរសារាយ ដែលជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និងចុងចម្លើយ ក្នុងចំណែកម្នាក់ៗចំនួន **១ ភាគ ២** ( **មួយភាគពីរ** ) ។

ច.អចលនវត្ថុទី៦៖ ទំហំ **២៨៨** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្លុង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតលក់ផ្ដាច់លេខ: **៨៥៤/១៣ បជ** ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ ដែលជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និងចុងចម្លើយ ក្នុងចំណែកម្នាក់ៗចំនួន **១ ភាគ ២** ( **មួយភាគពីរ** ) ។

ឆ.អចលនវត្ថុទី៧៖ ទំហំ **៣,២៥៣.៥៤** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្លុង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្ដាច់លេខ: **៣០៣២/២១ បជ** ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ ដែលជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និងចុងចម្លើយ ក្នុងចំណែកម្នាក់ៗចំនួន **១ ភាគ ២** ( **មួយភាគពីរ** ) ។

ជ.អចលនវត្ថុទី៨៖ ទំហំ **៥.៤១៦** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្លុង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្ដាច់លេខ: **៣០១៥/១៨ បជ** ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ ដែលជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និងចុងចម្លើយ ក្នុងចំណែកម្នាក់ៗចំនួន **១ ភាគ ២** ( **មួយភាគពីរ** ) ។

ឈ.អចលនវត្ថុទី៩៖ ទំហំ **៦៥៣.៥** ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិទួលខ្លុង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលិខិតលក់ផ្ដាច់លេខ: **០០៦៥/១៦ បជ** ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ដែលជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និងចុងចម្លើយ ក្នុងចំណែកម្នាក់ៗចំនួន **១ ភាគ ២** ( **មួយភាគពីរ** ) ។

ញ.អចលនវត្ថុទី១០៖ គ្មានទំហំ មានទីតាំងស្ថិតនៅភូមិស្នឹង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានកិច្ចសន្យាលក់ផ្ដាច់លេខ: **៣០១៦/១៨ បជ** ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ដែលជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និងចុងចម្លើយ ក្នុងចំណែកម្នាក់ៗចំនួន **១ ភាគ ២** ( **មួយភាគពីរ** ) ។

៣.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះបានបញ្ចប់នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈ **នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤** និងប្រកាសសាលក្រមជាអសាធារណៈ **នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤** ។

*ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។*

ថ្ងៃសុក្រ ១៤ កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

តាកែវ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

**បានឃើញ**

តាកែវ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤

**ចៅក្រម**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃសុក្រ ១៤ កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

តាកែវ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner